ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ធនាគារជាតិ នៃ កម្ពុជា

# សេចក្តីថ្លែងការណ៍រួម
# រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា

អនុលោមតាមកិច្ចប្រជុំរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ៖

១. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សូមជម្រាបមតិសាធារណៈ ថា បច្ចុប្បន្ននេះ មានក្រុមជនមួយចំនួនបង្ហាញខ្លួនជាអង្គការមិនមែនរដ្ឋាភិបាលជាសមាគមសប្បុរសធម៌ ឬជាសប្បុរសជន បានធ្វើការឲ្យខ្ចីប្រាក់តាមជនបទ និងទីប្រជុំជន ហើយចាត់ខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ សកម្មភាពឲ្យខ្ចីប្រាក់នេះពុំគ្រាន់តែគ្មានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាប៉ុណ្ណោះទេ ថែមទាំងយកការប្រាក់ខ្ពស់មានលក្ខណៈជាការកេងប្រវ័ញ្ច។ ប្រការនេះបានធ្វើឲ្យកូនបំណុលរបស់ខ្លួនធ្លាក់ក្នុងគ្រោះអាសន្នរើបំណុលមិនរួច ហើយធ្វើឲ្យគ្រួសារព្រាត់ប្រាស និងទ្រព្យសម្បត្តិហិនហោច។ ចំពោះមុខសភាពការណ៍ដូច្នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ថ្កោលទោស និងដាក់បទបញ្ជាដល់អង្គការ សមាគម ឬបុគ្គលទាំងនោះ ឲ្យបញ្ឈប់សកម្មភាពអកុសលនេះភ្លាម។ ក្នុងករណីដែលអង្គការ សមាគម ឬបុគ្គល ទាំងនោះចង់បន្តសកម្មភាពឲ្យខ្ចីប្រាក់ ត្រូវតែធ្វើឡើងក្នុងក្របខ័ណ្ឌច្បាប់ គឺត្រូវចូលខ្លួនមកសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដែលនឹងពិនិត្យគុណវុឌ្ឍិច្បាស់លាស់ត្រឹមត្រូវ មុននឹងផ្តល់។ ការរឹងរូសណាមួយដែលប្រឆាំងនឹងបទបញ្ជានេះ នឹងត្រូវទទួលទោសទណ្ឌតាមច្បាប់ជាធរមាន។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

២. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា ៖

ក. រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយគាំពារ និងលើកទឹកចិត្តឲ្យគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាបណ្ណនិងចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ពង្រីកបណ្តាញប្រតិបត្តិការឲ្យកាន់តែទូលំទូលាយ និងផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនិងតម្លាភាព ជូនប្រជាពលរដ្ឋទូទៅ។

ខ. ប្រទេសកម្ពុជាជាប្រទេសប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារ ដែលរាល់ការកំណត់ថ្លៃនិងអត្រាការប្រាក់គឺអាស្រ័យលើការប្រកួតប្រជែងទីផ្សារ។

គ. គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាគ្រឹះស្ថានដែលកាន់កាប់និងគ្រប់គ្រងដោយឯកជន មិនមែនជារបស់រដ្ឋឡើយ ។ គ្រឹះស្ថានទាំងនោះជា ស្ថាប័នស្វែងរកប្រាក់ចំណេញ ដើម្បីនិរន្តរភាពហិរញ្ញវត្ថុរបស់ខ្លួនក្នុងការបន្តផ្តល់ប្រាក់កម្ចីជូនដល់ប្រជាពលរដ្ឋ ពោលគឺមិនមែនជាអង្គការមនុស្សធម៌ដែលផ្តល់ប្រាក់ជំនួយឡើយ។ ប្រជាពលរដ្ឋដែលខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណនិងចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ត្រូវតែមានកាតព្វកិច្ចសងប្រាក់កម្ចីឲ្យគ្រឹះស្ថានវិញ។

៣. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា លើកទឹកចិត្តឲ្យប្រជាពលរដ្ឋពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយមុននឹងសម្រេចចិត្តខ្ចីប្រាក់។ ទន្ទឹមនឹងនេះ ក៏តម្រូវឲ្យគ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាជ្ញាបណ្ណនិងចុះបញ្ជីត្រូវវិភាគវាយតម្លៃអំពីសមត្ថភាពសងប្រាក់របស់អ្នកខ្ចី ហើយត្រូវមាន ការទទួលខុសត្រូវខ្ពស់ក្នុងការបង្ហាញព័ត៌មាននិងលក្ខខណ្ឌផ្សេងៗ ពាក់ព័ន្ធនឹងការខ្ចីប្រាក់ឲ្យបានច្បាស់លាស់ជូនដល់អ្នកខ្ចីប្រាក់។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥**